ទីស្តីការក្រសួងយុត្តិធម៌
លេខ ៣៥ ព្រ.រ.៩៧

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>សូមជម្រាបមក</u>**

**លោក ព្រះរាជអាជ្ញាអមតុលាការខេត្តកំពត**

**<u>សូមជ្រាប។</u>**

**<u>កម្មវត្ថុ:</u>** លិខិតរបស់លោកទៅស្នងការនគរបាលខេត្តកំពត ។

តាមលិខិតលេខ ១០ អ.ក.៩៧ ចុះថ្ងៃទី៣០ មករា ១៩៩៧ លោកព្រះរាជអាជ្ញាបានសរសេរទៅរំលឹកស្នងការនគរបាលខេត្តកំពត អំពីច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង សុំឱ្យស្នងការនគរបាលចាត់វិធានការបង្ក្រាបល្បែងយូគីក្នុងខេត្ត ។

វិធានការដែលលោកបានចាត់នេះជាការល្អណាស់ ។ បញ្ហានេះចូលក្នុងសមត្ថកិច្ចរបស់លោកដែលជាមន្ត្រីការពាររបៀបរៀបរយសាធារណៈហើយលោកមានសិទ្ធិពេញទីបញ្ជាទៅនគរបាលយុត្តិធម៌ ។

ខ្ញុំពេញចិត្តនឹងការងាររបស់លោកណាស់ ហើយសូមសរសើរយ៉ាងកក់ក្តៅ ។

សូមលោកបន្តបំពេញភារកិច្ចរបស់លោកឱ្យបានសកម្មយ៉ាងនេះតទៅមុខទៀត ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

<u>ចម្លងជូន</u>
- មហាអយ្យការអមសាលាឧទ្ធរណ៍
- អយ្យការតុលាការគ្រប់ខេត្ត-ក្រុង